**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយប្រទេសដៃគូសន្ទនាអាស៊ាន

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី សុខ ចិន្ដាសោភា** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសដៃគូសន្ទនាអាស៊ាន រួមមាន អូស្ត្រាលី កាណាដា ចិន សហភាពអឺរ៉ុប ឥណ្ឌា ជប៉ុន នូវែលសេឡង់ សាធារណរដ្ឋកូរ៉េ សហព័ន្ធរុស្ស៊ី និងចក្រភពអង់គ្លេស។

នៅក្នុងកិច្ចប្រជុំទាំងនោះ **ឯកឧត្ដម សុខ ចិន្ដាសោភា** បានសង្កត់ធ្ងន់លើចំណុចសំខាន់ៗដូចខាងក្រោម៖

- ចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ច និងការជំរុញពាណិជ្ជកម្ម និងវិនិយោគក្នុង និងរវាងតំបន់ នៅតែជាសសរស្ដម្ភសំខាន់ក្នុងទំនាក់ទំនងរបស់អាស៊ានជាមួយដៃគូខាងក្រៅ។ ដូចនេះ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី (FTA) ដែលអាស៊ានមានជាមួយប្រទេសដៃគូនានា និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ប្រកបដោយប្រសិទ្ធភាព និងពេញលេញ ដើម្បីពង្រឹងសមាហរណកម្មតំបន់ និងនាំមកនូវផលប្រយោជន៍កាន់តែច្រើនសម្រាប់ប្រជាជន។ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីតម្រូវការដែលអាស៊ានត្រូវសហការជាមួយប្រទេសដៃគូសន្ទនាផ្សេងៗទៀត ដើម្បីបង្កើតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីបន្ថែម និងដើម្បីធ្វើឱ្យប្រសើរឡើងនូវការឈានចូលក្នុងទីផ្សារ សុខដុមនីយកម្មក្របខ័ណ្ឌបទប្បញ្ញត្តិ និងការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម។

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 [illegible]
ទូរសារ : (855) 23 216 141, 023 [illegible]
អ៊ីម៉ែល : mfaic@mfaic.gov.kh

- ដើម្បីធានាបាននូវកំណើនយ៉ាងឆាប់រហ័ស និងយូរអង្វែង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជំរុញឱ្យអាស៊ាន និងប្រទេសដៃគូសន្ទនា ចាប់យកសក្តានុពលនៃឧស្សាហកម្មដ៏ខ្លាំងក្លាដែលកំពុងលេចឡើង រួមមាន សេដ្ឋកិច្ចឌីជីថល ការផ្លាស់ប្តូរបៃតង ខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយភាពធន់ និងទេសចរណ៍ប្រកបដោយចីរភាព។ ក្នុងចំណោមអាទិភាពសំខាន់ៗមួយចំនួននៅក្រោមសសរស្តម្ភសហគមន៍អាស៊ានទាំងបី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់លើកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថល ដែលជាកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលតំបន់ដំបូងគេក្នុងពិភពលោក ហើយរំពឹងថានឹងត្រូវអនុម័តនៅឆ្នាំក្រោយ ការបង្កើតបណ្តាញអគ្គិសនីអាស៊ានប្រកបដោយភាពធន់ ចីរភាព និងឆ្លាតវៃ និងការប្រើប្រាស់កាន់តែប្រសើរឡើងនៃថាមពលកកើតឡើងវិញ និងកម្រិតកាបូនទាប។
- ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះប្រទេសដៃគូសន្ទនាទាំងអស់ចំពោះការគាំទ្រឥតងាករេចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការពង្រឹងបន្ថែមទៀតនូវការតភ្ជាប់ក្នុងតំបន់។ ក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តដៃគូសន្ទនាទាំងអស់ឱ្យបន្តរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងនេះ រួមមានតាមរយៈការគាំទ្រដល់ការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) ២០២៥ និងផែនការបន្ទាប់។ តំបន់ដែលមានភាពធន់ និងទំនាក់ទំនងគ្នាទៅវិញទៅមកនឹងធានាបានថាអាស៊ាននៅតែជាចលករជំរុញដ៏សំខាន់នៃកំណើនក្នុងតំបន់ និងពិភពលោក។
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ផងដែរថា អាស៊ានត្រូវកសាងប្រព័ន្ធអេកូឡូស៊ីដើម្បីជួយសម្រេចបាននូវចក្ខុវិស័យទាំងនេះ តាមរយៈការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាបានថាប្រជាជនអាស៊ាន ទទួលបានជំនាញនៃសតវត្សទី២១ ដែលអនុញ្ញាតឱ្យពួកគេអភិវឌ្ឍន៍បាននាពេលអនាគត ធ្វើឱ្យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមមានភាពប្រកួតប្រជែង ផលិតភាព និងមានភាពធន់ និងសម្របសម្រួលការទទួលយកបច្ចេកវិទ្យា និងឧបករណ៍ឌីជីថល។ លើសពីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ដៃគូសន្ទនាទាំងអស់សម្រាប់ការបន្តគាំទ្រដល់ការអនុវត្តផែនការការងារនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) ទី៤ (២០២១-២០២៥) ដែលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការពង្រួមគម្លាតអភិវឌ្ឍន៍នៅក្នុងតំបន់។
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះដៃគូសន្ទនាសម្រាប់ការគាំទ្រចំពោះមជ្ឈភាព អាស៊ាន និងទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) ដែលជាឯកសារមគ្គុទេសន៍ក្នុងការទំនាក់ទំនងរបស់អាស៊ាន ជាមួយដៃគូក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងតំបន់មហាសមុទ្រឥណ្ឌា។ ជាងនេះទៅទៀត **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានលើកទឹកចិត្តប្រទេសដៃគូសន្ទនាឱ្យរួមចំណែកដល់ AOIP តាមរយៈគម្រោងជាក់ស្តែង និងជាក់លាក់

នៅក្នុងវិស័យអាទិភាពទាំងបួននៃ AOIP តាមរយៈយន្តការដឹកនាំដោយអាស៊ាន ដើម្បីផ្តល់ផលប្រយោជន៍ទៅវិញទៅមក ។

កិច្ចប្រជុំខាងលើបានអនុម័តឯកសារលទ្ធផលដូចខាងក្រោម៖

១. សេចក្តីថ្លែងការណ៍រួមរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន ស្តីពីការពង្រឹងសហប្រតិបត្តិការសកម្មភាពមីនមនុស្សធម៌

២. សេចក្តីថ្លែងការណ៍រួមរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី ប្រារព្ធខួបអនុស្សាវរីយ៍ ២០ ឆ្នាំ នៃការចូលរបស់រុស្ស៊ីជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC)

៣. សេចក្តីថ្លែងការណ៍រួមថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ចក្រភពអង់គ្លេស ស្តីពី៖ «ការពង្រឹងការតភ្ជាប់ដើម្បីអនាគតដែលប្រកបដោយវិបុលភាព ចីរភាព និងសន្តិសុខ»

៤. ផែនការសកម្មភាពដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-អូស្ត្រាលី ឆ្នាំ ២០២៥-២០២៩

ខណៈដែលកម្ពុជាបញ្ចប់តួនាទីជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-រុស្ស៊ី **ឯកឧត្តម សុខ ចិន្តាសោភា** បានថ្លែងអំណរគុណដល់សហការីអាស៊ានដែលបានគាំទ្រយ៉ាងពេញទំហឹងក្នុងរយៈពេលបីឆ្នាំកន្លងមក ហើយបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសមីយ៉ាន់ម៉ាដែលជាប្រទេសសម្របសម្រួលបន្ទាប់ ដើម្បីជានានូវការប្តូរវេនប្រកបដោយភាពរលូន និងប្រសិទ្ធភាព៕

ថ្ងៃសុក្រ ៦ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

វៀងចន្ទន៍ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤